ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៣៣ សហវ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣

# ប្រកាសរួម

## ស្តីពី

## ការផ្តល់រង្វាន់លើកទឹកចិត្តជូន

## ក្រសួងព្រះបរមរាជវាំង និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ NS / KRT - 34 ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងប្រកាសរួមលេខ ១៣២ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព្រះបរមរាជវាំង

## សម្រេច

**ប្រការ ១** :

ត្រូវបានផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនក្រសួងព្រះបរមរាជវាំង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត លើការបម្រើសេវាសាធារណៈ ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ ២** :

អនុញ្ញាតឱ្យក្រសួងព្រះបរមរាជវាំង កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់ ដោយដកយកពីប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈ ដូចបានកំណត់ដោយប្រកាសរួមលេខ ១៣២ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងព្រះបរមរាជវាំង។ ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់នេះ ត្រូវបានចាត់ទុកថា ថវិកាជាតិបានបើកផ្តល់ជាប្រាក់បុរេប្រទានជូនក្រសួងព្រះបរមរាជវាំង សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១ នៃប្រកាសរួមនេះ។ ប្រាក់រង្វាន់ដែលអនុញ្ញាតឱ្យកាត់ទុកជាមុននេះ រួមមានចំណែកប្រាក់រង្វាន់របស់ក្រសួងព្រះបរមរាជវាំង និងចំណែកប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣** :

ការផ្តល់ប្រាក់រង្វាន់ជូនក្រសួងព្រះបរមរាជវាំង និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជាសមាមាត្រភាគរយធៀបទៅនឹងប្រាក់ចំណូលប្រមូលបាន និងត្រូវបានបែងចែក ដូចខាងក្រោម ៖

- បង់ចូលថវិកាជាតិ ចំនួន ៣០% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងព្រះបរមរាជវាំង ចំនួន ៦៩% នៃចំណូលដែលប្រមូលបាន
- ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១% នៃចំណូលដែលប្រមូលបាន ៤

**ប្រការ ៤ :**

ក្រសួងព្រះបរមរាជវាំង ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ក្រសួងព្រះបរមរាជវាំង ត្រូវគ្រោងឥណទានប្រាក់រង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិកាជាតិ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់ក្រសួងព្រះបរមរាជវាំងដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើប្រាក់រង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់ ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលចាត់ទុកថាបានបុរេប្រទានពីថវិកាជាតិ(ប្រាក់ចំណូលដែលបានកាត់ទុកជាមុន)។

ការកត់ត្រាចំណូល និងចំណាយក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីទូទាត់ប្រាក់បុរេប្រទាន ដូចខាងក្រោម ៖

ក. **ផ្នែកចំណូល:** ត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ នូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន ៖ ក្រសួងព្រះបរមរាជវាំង ត្រូវរៀបចំ និងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាព ស្តីពីការអនុវត្តចំណូល និងតារាង ស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

ខ. **ផ្នែកចំណាយ:** ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ ៥ :**

ក្រោយពីបានបំពេញនីតិវិធី ដែលមានចែងក្នុងប្រការ ៤ ខាងលើ ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្ត ដូចខាងក្រោម ៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងព្រះបរមរាជវាំង ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែក

**ប្រការ ៦ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសរួមនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី**
**និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**

សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ **គង់ សំអុល**

ចម្លងជូន:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត

«ដើម្បីជូនជ្រាប»

- ដូចប្រការ ៧ «ដើម្បីមុខការ»